ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ

## របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិរួមមាន៖

- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅរាជធានី ខេត្ត

- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅក្រុង ស្រុក ខណ្ឌ
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅឃុំ សង្កាត់។

## ជំពូកទី២
## តួនាទីនិងបេសកកម្ម

**មាត្រា២ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិមានតួនាទីជាសេនាធិការឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងមានបេសកកម្មលើក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរួមទាំងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ភាពធន់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់របស់ប្រជាជននិងសហគមន៍។

## ជំពូកទី៣
## សមាសភាពនិងរចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី ខេត្ត

### ផ្នែកទី១
### គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី ខេត្ត

**មាត្រា៣ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងរាជធានី ខេត្ត | អនុប្រធាន |
| - ស្នងការនគរបាលរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | សមាជិក |
| - នាយកសាខាកាកបាទក្រហមកម្ពុជារាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរនិងអង្គភាពពាក់ព័ន្ធនៅរាជធានី ខេត្ត | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

**មាត្រា៤ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ដាក់ចេញគោលការណ៍ វិធានការដែលទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយរបស់រាជធានី ខេត្ត
- ដាក់ចេញផែនការត្រៀមបម្រុង ឆ្លើយតបសង្គ្រោះបន្ទាន់របស់រាជធានី ខេត្ត
- ពិនិត្យដោះស្រាយតម្រូវការសម្រាប់វិធានការការកាត់បន្ថយគ្រោះថ្នាក់និងការត្រៀមរៀបចំ
- ណែនាំអនុវត្តផែនការអភិវឌ្ឍន៍របស់មន្ទីរពាក់ព័ន្ធក្នុងរាជធានី ខេត្ត លើការធានាការធ្វើសមាហរណកម្ម ការត្រៀមបង្ការ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

- ណែនាំអនុវត្តសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការកម្មវិធីអភិវឌ្ឍន៍របស់ការិយាល័យក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ដឹកនាំសម្របសម្រួលនិងបញ្ជារាល់ប្រតិបត្តិការជួយសង្គ្រោះគ្រោះមហន្តរាយ
- សម្របសម្រួលជាមួយដៃគូជាអង្គការជាតិ អន្តរជាតិ ផ្នែកសាធារណៈ និងផ្នែកឯកជន ដើម្បីចូលរួមសហការក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍
- គ្រោងផែនការថវិកា ស្បៀង ប្រេងឥន្ធនៈ សម្ភារៈផ្សេងៗសម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញទៅនឹងគ្រោះមហន្តរាយ
- ចលនាតម្រូវការមូលនិធិនិងធនធានសម្ភារៈសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អំពីស្ថានការណ៍គ្រោះមហន្តរាយ ការប៉ាន់ប្រមាណ ការខូចខាត ការបាត់បង់ តម្រូវការ និងដំណើរការអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ
- ប្រកាសឱ្យដឹងមុនពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងហានិភ័យជូនដល់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

**មាត្រា៥ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ត្រូវប្រជុំមួយដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធានឬអនុប្រធានតាមការប្រគល់សិទ្ធិ។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត អាចអញ្ជើញមន្ទីរ អង្គភាពជុំវិញរាជធានី ខេត្ត មន្ត្រីជំនាញ ផ្នែកឯកជន និងសង្គមស៊ីវិល ចូលរួមពិគ្រោះយោបល់ សិក្សាស្រាវជ្រាវលើរាល់បញ្ហាដែលទាក់ទងក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយ។

ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានដែលទទួលបានការផ្ទេរសិទ្ធិត្រូវដឹកនាំកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត។

## ផ្នែកទី២
## លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ
## រាជធានី ខេត្ត

**មាត្រា៦ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត មានលេខាធិការដ្ឋានជាសេនាធិការរដ្ឋបាល និងបច្ចេកទេសគ្រប់គ្រងគ្រោះមហន្តរាយ ហើយក៏ជាមជ្ឈមណ្ឌលសម្របសម្រួលគ្រោះអាសន្នរាជធានី ខេត្ត ដែលមានសមាសភាពៈ

- អភិបាលរងរាជធានី ខេត្ត ១រូប ប្រធាន
- នាយករដ្ឋបាលសាលារាជធានី ខេត្ត អនុប្រធាន

- នាយករងរដ្ឋបាលសាលារាជធានី ខេត្ត ១រូប អនុប្រធានអចិន្ត្រៃយ៍
- មន្ត្រីទីចាត់ការចំណុះរដ្ឋបាលសាលារាជធានី ខេត្ត មួយចំនួន ជំនួយការ។

សមាសភាពជាក់ស្តែងនៃលេខាធិការដ្ឋានត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត មានទីតាំងនៅក្នុងសាលារាជធានី ខេត្ត និងមានសិទ្ធិប្រើត្រារបស់រដ្ឋបាលរាជធានី ខេត្ត។

**មាត្រា៧ .-**

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធានានិរន្តរភាពនៃដំណើរការរដ្ឋបាលរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត
- សម្របសម្រួលជាមួយអង្គភាព មន្ទីរជុំវិញរាជធានី ខេត្ត ក្នុងក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយ
- ប្រមូល វិភាគ ផ្សព្វផ្សាយ និងទុកដាក់ទិន្នន័យគ្រោះមហន្តរាយ
- រៀបចំគោលការណ៍ វិធានការ ដែលទាក់ទងការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ដាក់ជូនសុំការយល់ព្រមពីប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត
- តាមដាននិងត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិ ផែនការជាតិ និងគោលការណ៍ ផែនការរាជធានី ខេត្ត លើការគ្រប់គ្រងគ្រោះមហន្តរាយ
- ពិនិត្យភាពងាយរងគ្រោះនិងវិធានការត្រៀមបង្ការជាក់លាក់ឬការកាត់បន្ថយគ្រោះថ្នាក់
- ដាក់ចេញវិធានការសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីអង្គភាព មន្ទីរពាក់ព័ន្ធជុំវិញរាជធានី ខេត្ត លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ សម្រាប់ប្រតិបត្តិ
- វាយតម្លៃការត្រៀមរៀបចំនៅគ្រប់អង្គភាព មន្ទីរពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងរាជធានី ខេត្ត ដើម្បីធានាថាមានការត្រៀមរៀបចំរួចរាល់សម្រាប់ឆ្លើយតបគ្រោះមហន្តរាយ
- សម្របសម្រួលការឆ្លើយតបក្នុងព្រឹត្តិការណ៍គ្រោះមហន្តរាយ
- ផ្តល់នូវចំណាត់ការដល់អង្គភាព មន្ទីរពាក់ព័ន្ធ អាជ្ញាធរក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចំពោះសកម្មភាពដែលត្រូវប្រកាន់យកក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ
- រៀបចំវេទិកា ទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចប្រជុំនានា
- អប់រំទូទៅ ការយល់ដឹង និងការបណ្តុះបណ្តាលដល់សហគមន៍លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- ផ្តល់នូវជំនួយបច្ចេកទេសចាំបាច់ឬផ្តល់យោបល់ដល់អាជ្ញាធរក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយឱ្យកាន់តែមានប្រសិទ្ធភាព
- លើកគម្រោងថវិកាទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយជូនរដ្ឋបាលរាជធានី ខេត្ត
- ពិនិត្យនិងផ្តល់យោបល់លើការងារសាងសង់ក្នុងតំបន់ដែលនឹងអាចកើតមានហានិភ័យគ្រោះមហន្តរាយជូនប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត

- ជួយរៀបចំកិច្ចការបញ្ជានិងហ្វឹកហាត់ការគ្រប់គ្រងគ្រោះមហន្តរាយជាទៀងទាត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី ខេត្ត។

## ផ្នែកទី៣
## ក្រុមប្រតិបត្តិការគ្រោះមហន្តរាយ

**មាត្រា៨ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ត្រូវរៀបចំក្រុមប្រតិបត្តិការសម្រាប់ជួយ សង្គ្រោះគ្រោះមហន្តរាយរួមមាន៖

១. ក្រុមរុករកសង្គ្រោះនិងសន្តិសុខមានតួនាទី៖
- ជម្លៀសទៅទីសុវត្ថិភាព
- សង្គ្រោះក្នុងតំបន់រងគ្រោះ
- ការពារសន្តិសុខទីស្នាក់អាស្រ័យបណ្តោះអាសន្ននិងតំបន់រងគ្រោះ។

២. ក្រុមឆ្លើយតបសង្គ្រោះបន្ទាន់មានតួនាទី៖
- ផ្តល់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- ផ្តល់ទឹកស្អាតនិងអនាម័យ
- ផ្តល់ជម្រក
- ផ្តល់ការថែទាំសុខភាព
- ផ្តល់ការគាំពារ
- ផ្តល់ការអប់រំ។

៣. ក្រុមស្តារឡើងវិញមានតួនាទី៖
- ស្តារឡើងវិញជាបឋមនូវជីវភាពរស់នៅរបស់ប្រជាជននិងសហគមន៍
- ស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ។

ក្រុមនីមួយៗត្រូវដឹកនាំដោយអភិបាលរងរាជធានី ខេត្ត។ សមាសភាពជាក់ស្តែងនៃក្រុមនីមួយៗត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

## ជំពូកទី៤
## សមាសភាពនិងរចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង ស្រុក ខណ្ឌ

## ផ្នែកទី១
## គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ

**មាត្រា៩ .-**

ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន |
| - អភិបាលរងក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| - អធិការនគរបាលក្រុង ស្រុក ខណ្ឌ | សមាជិក |
| - មេបញ្ជាការផ្នែកកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ | សមាជិក |
| - មេបញ្ជាការផ្នែកសឹករងក្រុង ស្រុក ខណ្ឌ | សមាជិក |
| - ប្រធានអនុសាខាកាកបាទក្រហមក្រុង ស្រុក ខណ្ឌ | សមាជិក |

- ប្រធានការិយាល័យនិងអង្គភាពពាក់ព័ន្ធនៅក្រុង ស្រុក ខណ្ឌ សមាជិក។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា១០.-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តគោលការណ៍ដែលទាក់ទងការគ្រប់គ្រងគ្រោះមហន្តរាយ
- កសាងផែនការត្រៀមរៀបចំនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ ផ្អែកលើមុខសញ្ញាគ្រោះថ្នាក់និងវិភាគភាពងាយរងគ្រោះដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដានត្រួតពិនិត្យជាបន្តបន្ទាប់មុខសញ្ញាគ្រោះថ្នាក់ ហានិភ័យ ភាពគំរាមកំហែងគ្រោះមហន្តរាយ និងលក្ខខណ្ឌនៃប្រជាជនងាយរងគ្រោះ
- រៀបចំគោលការណ៍ណែនាំសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមរៀបចំ និងការឆ្លើយតប
- កំណត់សេចក្តីត្រូវការបណ្តុះបណ្តាល ដឹកនាំការអប់រំបណ្តុះបណ្តាលនិងកម្មវិធីការយល់ដឹងជាសាធារណៈ
- សម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋានទៅនឹងការជានាសកម្មភាពពេលមានគ្រោះមហន្តរាយអាចរ៉ាប់រងបានយ៉ាងឆាប់រហ័សនិងមានប្រសិទ្ធភាព
- អនុវត្តការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនិងធ្វើឱ្យបានសម្រេចដូចក្នុងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ
- ពិនិត្យផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ដើម្បីធានាថា ឃុំ សង្កាត់ បានបញ្ជ្រាបវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំ សង្កាត់
- លើកទឹកចិត្តនិងសម្រួលដល់ផ្នែកឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ក្រុមសហគមន៍ក្នុងការឆ្លើយតបនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- កំណត់អគារ ទីធ្លា ក្នុងក្រុង ស្រុក ខណ្ឌដែលអាចប្រើប្រាស់សម្រាប់ជម្លៀសប្រជាពលរដ្ឋមកស្នាក់នៅបណ្តោះអាសន្នឬធ្វើជាមណ្ឌលជួយសង្គ្រោះគ្រោះមហន្តរាយ
- កំណត់ជាមុននូវកន្លែងផ្គត់ផ្គង់សម្ភារៈជួយសង្គ្រោះ ដើម្បីធានាថានឹងអាចរកបានយ៉ាងឆាប់បំផុតពេលត្រូវការ
- ចលនាតម្រូវការមូលនិធិ ធនធានសម្ភារៈ និងមធ្យោបាយសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
- ធ្វើរបាយការណ៍ជូនប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត។

**មាត្រា១១.-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌត្រូវប្រជុំយ៉ាងតិចមួយដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌអាចអញ្ជើញអង្គភាព ការិយាល័យពាក់ព័ន្ធ ផ្នែកឯកជន និងសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ ចូលរួមប្រជុំក្នុងក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយ។

## ផ្នែកទី២
## លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ
## ក្រុង ស្រុក ខណ្ឌ

**មាត្រា១២ .-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការរដ្ឋបាលនិងបច្ចេកទេសជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលរងក្រុង ស្រុក ខណ្ឌ ១រូប | ប្រធាន |
| - នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | អនុប្រធានអចិន្ត្រៃយ៍ |
| - មន្ត្រីការិយាល័យចំណុះរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ មួយចំនួន | ជំនួយការ។ |

សមាសភាពជាក់ស្តែងនៃលេខាធិការដ្ឋានត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា១៣ .-**

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌមានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធានានិរន្តរភាពនៃដំណើរការការងាររដ្ឋបាលរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ
- ចូលរួមរៀបចំការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលមូលដ្ឋាននិងសហគមន៍អំពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បង្កើត ថែទាំ ពិនិត្យឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធប្រាស្រ័យទាក់ទងនិងប្រកាសឱ្យដឹងមុន
- តាមដាននិងត្រួតពិនិត្យជាប្រចាំនូវព្រឹត្តិការណ៍គ្រោះមហន្តរាយដើម្បីធានាការជួយគាំទ្រដល់សហគមន៍ដែលរងប៉ះពាល់ទាន់ពេលវេលា
- ប្រកាន់ខ្ជាប់ការរាយការណ៍បន្ទាន់អំពីស្ថានភាពគ្រោះមហន្តរាយនិងការទាក់ទងជាប្រចាំជាមួយលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត
- រៀបចំរបាយការណ៍ដាក់ជូនប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៥
## សមាសភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ
## ឃុំ សង្កាត់

**មាត្រា១៤ .-**

សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់មានដូចខាងក្រោម៖

| | |
|---|---|
| - មេឃុំឬចៅសង្កាត់ | ប្រធាន |
| - ជំទប់ឬចៅសង្កាត់រង ១រូប | អនុប្រធាន |
| - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | សមាជិក |
| - នាយប៉ុស្តិ៍នគរបាលរដ្ឋបាល | សមាជិក |

- នាយកសាលានៅក្នុងឃុំ សង្កាត់ សមាជិក
- ប្រធានមណ្ឌលសុខភាពឬប៉ុស្តិ៍សុខភាព សមាជិក
- ជនបង្គោលទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ សមាជិក
- ភ្នាក់ងារសុខភាពសត្វ សមាជិក
- អ្នកស្ម័គ្រចិត្តនិងយុវជនកាកបាទក្រហមកម្ពុជា សមាជិក
- ព្រឹទ្ធាចារ្យក្នុងឃុំ សង្កាត់ សមាជិក
- មេភូមិគ្រប់ភូមិ សមាជិក
- ស្មៀន លេខាធិការ។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ត្រូវតែងតាំងដោយដីការបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**មាត្រា១៥ ._**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់មានតួនាទីភារកិច្ចដូចខាងក្រោមៈ

- អនុវត្តគោលការណ៍ណែនាំដែលទាក់ទងការគ្រប់គ្រងគ្រោះមហន្តរាយ
- សមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំ សង្កាត់
- រៀបចំបង្កើតក្រុមប្រតិបត្តិការសម្រាប់ធ្វើសកម្មភាពរួមមានៈ
  - ក្រុមជួយសង្គ្រោះ
  - ក្រុមសុខភាពនិងអនាម័យ
  - ក្រុមឆ្លើយតបនិងព័ត៌មាន
- ផ្សព្វផ្សាយព័ត៌មាននិងអប់រំការយល់ដឹងជាសាធារណៈដល់ប្រជាជនក្នុងឃុំ សង្កាត់ អំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- រាយការណ៍បន្ទាន់ពីស្ថានភាពហានិភ័យគ្រោះមហន្តរាយនិងលើកសំណូមពរជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ
- ធ្វើប្រតិបត្តិការសង្គ្រោះបន្ទាន់ក្នុងឃុំ សង្កាត់ ពេលមានគ្រោះមហន្តរាយកើតឡើង
- ចលនាតម្រូវការមូលនិធិ ធនធានសម្ភារៈ និងមធ្យោបាយសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
- ជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ តាមដានត្រួតពិនិត្យនិងផ្តល់យោបល់លើសកម្មភាពការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរបស់ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ផ្នែកឯកជន អង្គការជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

## ជំពូកទី៦
## ប្រភពធនធាននិងមូលនិធិ

**មាត្រា១៦ ._**

ការចំណាយសម្រាប់ដំណើរការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនិតិវិធីច្បាប់ជាធរមាននូវធនធាននិងមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

អនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៨ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ